**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

********

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌលេខ: ១២៨ "ក្រ២"

ចុះថ្ងៃទី ១៧.០២.២០២០

សំណុំរឿងព្រហ្មទណ្ឌលេខ: ១២៥

ចុះថ្ងៃទី ០៨.០១.២០១៩

សំណុំរឿងស៊ើបសួរលេខ ៣១៥

ចុះថ្ងៃទី ២៥.០១.២០១៩

ជំនុំជម្រះលេខ: ៥៥៣៨

ចុះថ្ងៃទី ២២.១១.២០១៩

# នាមប្រជារាស្ត្រខ្មែរ

# សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជំនុំជម្រះជាសាធារណៈ នៅសាលសវនាការនៃសាលាដំបូងរាជធានីភ្នំពេញ នាថ្ងៃទី២៧ ខែមករា ឆ្នាំ២០២០ វេលាម៉ោង ៨:០០ នាទីព្រឹក ដោយមានសមាសភាពចូលរួមដូចតទៅ:

## ក្រុមប្រឹក្សាជំនុំជម្រះ

-លោកស្រីចៅក្រម [redacted] ជាប្រធានក្រុមប្រឹក្សា

-លោកស្រីអនុប្រធាន [redacted] ជាចៅក្រមប្រឹក្សា

-លោកចៅក្រម [redacted] ជាចៅក្រមប្រឹក្សា

## តំណាងអយ្យការ

-លោកស្រី[redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

## ក្រឡាបញ្ជីសវនាការ

-កញ្ញា [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ១២៥ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩ ដែលមានជនជាប់ចោទ៖

១-ឈ្មោះ [redacted] ឡេងប៊ុនរ៉ា ហៅ ផាន់ណា ភេទប្រុស អាយុ៣១ឆ្នាំ ជនជាតិខ្មែរ មានទីកន្លែងកំណើតស[redacted] ក្រុងភ្នំពេញ បច្ចុប្បន្នកំពុងឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី១ ឪពុកឈ្មោះ [redacted] ប៊ុនធី "រ" ម្តាយឈ្មោះ [redacted] យឿន "រ" ប្រពន្ធឈ្មោះ [redacted] សុគន្ធារី ជានីតិជន ទោសពីមុនធ្លាប់ជាប់ពន្ធនាគាររយៈពេល០១ឆ្នាំ ពីបទៈ ចែកចាយគ្រឿងញៀន។

-ដីកាបង្គាប់ឱ្យឃុំខ្លួន(បន្ថែម) លេខ ៨២៩៤ "ជ" ដ.ឃ.ដ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៩។

-មានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] ឡេងប៊ុនរ៉ា ដែលមានការិយាល័យនៅអាគារផាកវេ ជាន់ទី១ មហាវិថីម៉ៅសេទុង (ផ្លូវលេខ២៤៥) សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ។

២-ឈ្មោះ [redacted] រ៉ាប៊ូ ភេទប្រុស អាយុ៣២ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើតនៅ[redacted] ក្រុងភ្នំពេញ បច្ចុប្បន្នកំពុងឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី១ ឪពុកឈ្មោះ [redacted] សារឿន "រ" ម្តាយឈ្មោះ [redacted] ថាន "រ" ប្រពន្ធឈ្មោះ លាភ "រ" ទោសពីមុនគ្មាន ជានីតិជន។

-ដីកាបង្គាប់ឱ្យឃុំខ្លួន(បន្ថែម) លេខ: ៨២៩៥ "ជ" ដ.ឃ.ដ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៩។

-មានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] រ៉ាប៊ូ ដែលមានការិយាល័យនៅផ្ទះលេខ៥អេ ផ្លូវលេខ២៨៥ សង្កាត់បឹងកក់១ ខណ្ឌទួលគោក រាជធានីភ្នំពេញ។

៣-ឈ្មោះ [redacted] សុខី ភេទស្រី អាយុ២៣ឆ្នាំ ជនជាតិខ្មែរ មានទីកន្លែងកំណើត [redacted] ក្រុងភ្នំពេញ បច្ចុប្បន្នកំពុងឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី២ ឪពុកឈ្មោះ [redacted] ណារិន "រ" ម្តាយឈ្មោះ [redacted] ចាន់ថន "រ" ប្តីឈ្មោះ [redacted] ពន្លក "រ" ជានីតិជន ទោសពីមុនគ្មាន។

-ដីកាបង្គាប់ឱ្យឃុំខ្លួន(បន្ថែម)លេខ ៨២៩៦ "ជ" ដ.ឃ.ដ ចុះថ្ងៃទី០៧ ខែសីហា ឆ្នាំ២០១៩។

-មានលោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] សុខី ដែលមានការិយាល័យនៅអាគារផាកវេ ជាន់ទី១ មហាវិថីម៉ៅសេទុង (ផ្លូវលេខ២៤៥) សង្កាត់ទួលស្វាយព្រៃទី១ ខណ្ឌចំការមន រាជធានីភ្នំពេញ។

ជាប់ចោទពីបទ: លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចផ្ទះលេខ២២ ផ្លូវបេតុង ភូមិម័ល សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៤-ឈ្មោះ [redacted] សុថារិទ្ធ ភេទប្រុស អាយុ៣១ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើត [redacted] ក្រុងភ្នំពេញ មានទីលំនៅបច្ចុប្បន្នស្នាក់ [redacted] រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ផាន់ណា "រ" ម្តាយឈ្មោះ [redacted] សុម៉ាលី "រ" ប្រពន្ធឈ្មោះ [redacted] កែវរដ្ឋា "រ" កូនគ្មាន ទោសពីមុនគ្មាន ជានីតិជន។

៥-ឈ្មោះ [redacted] ណារ៉ុង ហៅ ស្វិត ភេទប្រុស អាយុ៣៣ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ មានទីកន្លែងកំណើតនៅ [redacted] ក្រុងភ្នំពេញ មានទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះជួល សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ណារិន "រ" ម្តាយឈ្មោះ [redacted] គន្ធា "រ" ទោសពីមុនគ្មាន ជានីតិជន។

ជាប់ចោទពីបទ: **ទទួលផលចោរកម្ម** ប្រព្រឹត្តនៅចំណុចក្នុងកាស៊ីណូណាហ្គារាជធានីភ្នំពេញ កាលពីអំឡុងខែតុលា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ។

-ជនរងគ្រោះឈ្មោះ [redacted] សាលា ភេទស្រី អាយុ៣៦ឆ្នាំ ជនជាតិខ្មែរ មានទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះលេខ ២២ ផ្លូវបេតុង ភូមិម័ល(បុរីហុកឆេង) សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ។

## អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ វេលាម៉ោង០៣ និង១០នាទីរសៀល មានករណីលួចមានស្ថានទម្ងន់ទោស (រថយន្តម៉ាកតូយ៉ូតា កាម៉ារី) ពណ៌ទឹកមាស សេរីឆ្នាំ២០០៣ លេខតួ ៧៤៦៦៦០៧ លេខម៉ាស៊ីន ១៩០៤៧៨ ពាក់ស្លាកលេខ ភ្នំពេញ ២AB-៨១៣១ នៅចំណុចមុខផ្ទះលេខ២២ ផ្លូវបេតុង ភូមិម័ល សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ជាកម្មសិទ្ធិរបស់ឈ្មោះ [redacted] សាលា ភេទស្រី ដែលបានយករថយន្តខាងលើទៅចតនៅមុខផ្ទះ ហើយជនរងគ្រោះក៏បានចូលទៅសម្រាកក្នុងផ្ទះ។ ខណៈពេលជនត្រូវចោទទាំងបីនាក់ដែលមានឈ្មោះ [redacted] ឡេងប៊ុនរ៉ា ហៅ ផាន់ណា ភេទប្រុស ឈ្មោះ [redacted] រ៉ាប៊ូ ភេទប្រុស និងឈ្មោះ [redacted] សុខី បានជិះរថយន្តមកដល់ចំណុចមុខផ្ទះខាងលើ ក៏ឃើញរថយន្តមួយគ្រឿងខាងលើចតទុកនោះ ឃើញស្ងាត់មិនមានមនុស្ស ឈ្មោះ [redacted] ឡេងប៊ុនរ៉ា បានធ្វើសកម្មភាពដោយយកឧបករណ៍ដែកសំប៉ែតមុខស្រួចសម្រាប់កាច់បំបែកសោចេញ ពីហោប៉ៅខោរបស់វាទៅកាច់បំបែកសោទ្វាររថយន្តរបស់

ជនរងគ្រោះ រួចក៏ចូលទៅក្នុងរថយន្តបន្តកាច់បំបែកសោកុងតាក់រថយន្តបានសម្រេច ចំណែកឈ្មោះ [redacted] រ៉ាបូ និងឈ្មោះ [redacted] សុខី អង្គុយនៅក្នុងរថយន្តរបស់ឈ្មោះ [redacted] ឡេងប៊ុនរ៉ា ចាំមើលផ្លូវ។ បន្ទាប់ពីឈ្មោះ [redacted] ឡេងប៊ុនរ៉ា កាច់បំបែកសោរកុងតាក់រថយន្តរួចហើយ ក៏បញ្ឆេះរថយន្តនោះជិះគេចខ្លួន ចំណែកឈ្មោះ [redacted] រ៉ាបូ និងឈ្មោះ [redacted] សុខី បើករថយន្តរបស់ឈ្មោះ [redacted] ឡេងប៊ុនរ៉ា ចេញទៅបាត់ទៅ។ ឈ្មោះ [redacted] ឡេងប៊ុនរ៉ា បន្ទាប់ពីលួចបានហើយ ក៏បានយកទៅឱ្យឈ្មោ[redacted] សុថារិទ្ធ ដើម្បីយកដាក់បញ្ចាំនៅនឹងឈ្មោះ [redacted] សារ៉ុង ដែលទទួលបញ្ចាំនៅណាហ្គាវើល។

-បានឃើញ របាយការណ៍សំយោគលេខ ៤៤៩/២០១៨ រ.ប.ក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨ របស់ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតស្រាល នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ។

-បានឃើញ ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ២៧៣ អ.យ.ត ចុះថ្ងៃទី២២ ខែមករា ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសន្និដ្ឋានស្ថាពរលេខ ៤៦១៥ អ.យ.ប ចុះថ្ងៃទី០៤ ខែតុលា ឆ្នាំ២០១៩ របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញ ដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៥៨០៤ "ជ" ដ.ជ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ ២០១៩ របស់ចៅក្រមស៊ើបសួរ នៃសាលាដំបូងរាជធានីភ្នំពេញ។

## នាពេលសវនាការ

-ជនជាប់ចោទឈ្មោះ [redacted] ឡេងប៊ុនរ៉ា ហៅ ផាន់ណា បានឆ្លើយថា: កាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ វេលាម៉ោងប្រហែល ២ និង០០នាទី ខ្លួន ឈ្មោះ [redacted] រ៉ាបូ និងឈ្មោះ [redacted] សុខី ភេទស្រី បានបបួលគ្នាជិះរថយន្តដើម្បីធ្វើសកម្មភាពលួចឡានគេ។ ពេលជិះមកដល់ចំណុចកើតហេតុ ពួកខ្លួនបានឃើញឡានរបស់គេម៉ាក តូយ៉ូតា បាឡែន សេរីឆ្នាំ២០០៣ ដែលបានចតទុកចោលមុខនៅផ្ទះក្រៅរបង ពេលនោះ ខ្លួន និងឈ្មោះ [redacted] រ៉ាបូ ក៏បានចុះធ្វើសកម្មភាពយកសោកែច្នៃទៅចាក់សោទ្វាររថយន្ត រួចហើយពួកខ្លួនចាក់សោបញ្ឆេះជិះចេញទៅតែម្តង។ ពេលខ្លួនធ្វើសកម្មភាពឈ្មោះ [redacted] រ៉ាបូ ជាអ្នកមើលផ្លូវ ចំពោះឈ្មោះ [redacted] សុខី ជាអ្នកជិះបិទគូទពីក្រោយរហូតដល់ផ្ទះ ហើយខ្លួនក៏បានយករថយន្តនេះទៅទុកនៅក្នុងឃ្លាំងនៅតាខ្មៅរហូតដល់ព្រឹកស្អែក ទើបខ្លួនបានយកឡាននេះ ទៅលក់នៅម៉ុំណាហ្គាវើល ពេលបានប្រាក់ហើយ ខ្លួនក៏បានចែកប្រាក់ទៅឈ្មោះ [redacted] រ៉ាបូ និងឈ្មោះ [redacted] សុខី ផងដែរ។

-ជនជាប់ចោទឈ្មោះ [redacted] រ៉ាបូ បានឆ្លើយថា: កាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ វេលាម៉ោងមិនចាំតែយប់ជ្រៅ ខ្លួននិងឈ្មោះ [redacted] ឡេងប៊ុនរ៉ា រួមជាមួយឈ្មោះ [redacted] សុខខី បានបបួលគ្នាជិះឡានដើររកលួចរថយន្តគេដែលចតនៅមុខផ្ទះ។ ពេលនោះឈ្មោះ [redacted] ឡេងប៊ុនរ៉ា បានចុះពីលើរថយន្តធ្វើសកម្មភាពលួចយកឡានដែលគេចតទុកចោរនោះ ចំណែកខ្លួននៅឈរចាំមើលផ្លូវ ហើយឈ្មោះ [redacted] សុខី នៅក្នុងឡាន។ ពេលលួចបានហើយ ខ្លួននិងឈ្មោះ លឹម ឡេងប៊ុនរ៉ា បានជិះរថយន្តទៅជាមួយគ្នារហូតដល់ផ្ទះ។ ចំណែកឈ្មោះ [redacted] សុខី ជាអ្នកជិះឡានបិទគូទពីក្រោយ។ ពេលយកឡានទុករួចរាល់ហើយ ខ្លួន និងឈ្មោះ [redacted] សុខី ក៏បែកផ្លូវគ្នាទៅផ្ទះរៀងៗខ្លួន ហើយខ្លួនក៏ពុំដឹងថា [redacted] ឡេងប៊ុនរ៉ា បានយករថយន្តដែលលួចបាននេះទៅលក់នៅឯណាដែរ ប៉ុន្តែខ្លួនបានទទួលចំណែករបស់ខ្លួនដែលលក់រថយន្តបានចំនួន ២០០$ ទៅ ៣០០$។/

-ជនជាប់ចោទឈ្មោះ [redacted] សុខី បានឆ្លើយថា: នៅថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ វេលាម៉ោង ១ និង០០នាទី ឈ្មោះ [redacted] ឡេងប៊ុនរ៉ា និងឈ្មោះ [redacted] រ៉ាំបូ បានបបួលខ្លួនឱ្យជូនគាត់ទៅយកឡាន ប៉ុន្តែខ្លួនមិនដឹងថា ទៅយកនៅឯណាទេ។ ពេលខ្លួនទៅដល់កន្លែងកើតហេតុ ក៏បានឃើញឡានម៉ាក តូយូតា កាមរី ពណ៌ទឹកមាស ឆ្នាំ២០០៣ បានចតទុកនៅមុខផ្ទះ ហើយពេលនោះឈ្មោះ [redacted] ឡេងប៊ុនរ៉ា និងឈ្មោះ [redacted] រ៉ាំបូ ក៏បានធ្វើសកម្មភាពយកសោទៅចាក់បំបែកសោទ្វារឡាន រួចហើយក៏បើករថយន្តនោះជិះទៅតែម្តង។ ចំណែកខ្លួនជាអ្នកជិះរថយន្តតាមពីក្រោយ។ នៅពេលលួចបានហើយ ពួកខ្លួនក៏បានយករថយន្តនេះ ទៅទុកនៅឃ្លាំងនៅឯក្រុងតាខ្មៅ រួចក៏ជិះទៅផ្ទះរៀងៗខ្លួន។ បន្ទាប់មកឈ្មោះ លឹម ឡេងប៊ុនរ៉ា បានយកប្រាក់ចំនួន ២០០$ ទៅ ៣០០$ មកឱ្យខ្លួន។

-ជនជាប់ចោទឈ្មោះ [redacted] សុថារិទ្ធ បានឆ្លើយថា: កាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ វេលាម៉ោង ៧ ព្រឹក ឈ្មោះ លឹម ឡេងប៊ុនរ៉ា បានយករថយន្តទៅដាក់បញ្ចាំឱ្យឈ្មោះ [redacted] ណារ៉ុង រួចហើយឈ្មោះ [redacted] ឡេងប៊ុនរ៉ា បានឱ្យប្រាក់មកខ្លួនចំនួន ១០០$។ក្រោយមកខ្លួនក៏មិនបានដឹងថា ឡាននេះយកទៅលក់ឱ្យអ្នកណាបន្តទៀតទេ។

-តាមអំណានចម្លើយដើមបណ្តឹងឈ្មោះ [redacted] សាល បានឆ្លើយនៅដំណាក់កាលរបស់សមត្ថកិច្ចថា: កាលពីថ្ងៃទី ២៥ ខែតុលា ឆ្នាំ២០១៨ វេលាម៉ោង ៥ ខ្លួនពុំបានបើករថយន្តនេះទៅណាទេ គឺខ្លួននិងក្រុមគ្រួសារទុកនៅមុខផ្ទះរហូត។ លុះម៉ោង ២ ទៀបភ្លឺ ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ ខ្លួនភ្ញាក់ពីដេក អើតមើលរថយន្តខ្លួន ឃើញនៅកន្លែងដែលចតទុក ហើយខ្លួនក៏ចូលដេកវិញ។ លុះដល់ម៉ោង ៦ និង៣០នាទីព្រឹក ខណៈពេលដែលខ្លួនត្រូវជូនកូនទៅសាលា ស្រាប់តែមិនឃើញឡាន ហើយបន្ទាប់មកខ្លួនក៏ដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍រដ្ឋបាលដង្កោតែម្តង។

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា: ក្រោយពីបានស្តាប់ចម្លើយសារភាពលើជនជាប់ចោទទាំងបួននាក់នេះរួចមក ឃើញថា ការប្រព្រឹត្តរបស់ជនជាប់ចោទគឺពិតជាបានគាស់ទម្លុះទម្លាយយករថយន្តប្រាកដមែន។ ជនជាប់ចោទបានឆ្លើយសារភាពហើយថាបានលួចរថយន្តបានចំនួនរហូតទៅដល់ ១៦គ្រឿង ហើយឃើញថា ជនជាប់ចោទទាំងបីនាក់គឺពិតជាបានលួចយកគ្រឿងរបស់ជនរងគ្រោះដោយមានបានគាស់ទម្លុះទម្លាយប្រាកដមែន។ ម្យ៉ាងទៀតចំពោះឈ្មោះ [redacted] សុថារិទ្ធ បន្ទាប់ពីឈ្មោះ [redacted] ឡេងប៊ុនរ៉ា លួចរថយន្តគេបានហើយក៏បានពឹងឱ្យឈ្មោះ [redacted] សុថារិទ្ធ ជួយរកម៉ូយដើម្បីយករថយន្តនេះទៅ ចំណែកឈ្មោះ សោម ណារ៉ុង ក៏បានទទួលទិញរថយន្តនេះពីឈ្មោះ [redacted] ឡេងប៊ុនរ៉ា ប្រាកដមែន។ ដូចនេះ តំណាងអយ្យការនៅតែតម្កល់ការចោទប្រកាន់ទៅលើជនជាប់ចោទទាំងបីនាក់ ពីបទ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា តាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ ចំណែកឈ្មោះ [redacted] សុថារិទ្ធ និងឈ្មោះ [redacted] ណារ៉ុង ពីបទ: ទទួលផលចោរកម្ម និងសូមតម្កល់ដីកាសន្និដ្ឋានស្ថាពរលេខ ៤៦១៥ អ.យ.ប ចថ្ងៃទី០៤ ខែវិច្ឆិកា ឆ្នាំ២០១៩ ទុកនៅដដែល និងស្នើសុំឱ្យលោកស្រីប្រធានក្រុមប្រឹក្សាមត្តាពិនិត្យ និងសម្រេចផ្តន្ទាទោសជនល្មើសតាមច្បាប់។

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទទាំងបីនាក់ បានធ្វើសេចក្តីសន្និដ្ឋានថា: ឆ្លងកាត់ការសួរដេញដោលនាពេលសវនាការ ក៏ដូចជាចម្លើយនៅគ្រប់ដំណាក់កាលនេះគឺកូនក្តីខ្លួនបានសារភាពនូវទោសកំហុសរបស់គាត់ដែលគាត់បានប្រព្រឹត្តប្រាកដមែន។ មួយវិញទៀត ទាក់ទងនឹងសំណុំរឿងរបស់ពួកគាត់ដែរបានកើតឡើងគឺមានឡានចំនួន១៦គ្រឿង គឺមាន១៦ករណី ប៉ុន្តែដោយរឿងផ្សេងទៀតដែលកាត់កន្លងមកគឺជាបទល្មើសរឿង លួច មិនមែនជារឿងលួចដោយមានការប្រើហិង្សានោះទេ។ កូនក្តីខ្លួនបានបញ្ជាក់រួចហើយ ក៏ដូចជាអង្គសវនាការបញ្ជាក់ផង

ដែរថា ការប្រព្រឹត្តសកម្មភាពរបស់គាត់គឺជាការប្រព្រឹត្តដោយយកសោរចាក់ធម្មតា ហើយបញ្ចេះធម្មតាគឺពុំមានការចាក់បំបែកសោរ ឬក៏ប្រើអំពើហិង្សាណាមួយនោះឡើយ។ ដូច្នេះហើយផ្អែកតាមអង្គហេតុនេះ បទល្មើសដែលគាត់ប្រព្រឹត្តនេះគឺត្រឹមតែអំពើលួចតែប៉ុណ្ណោះ។ មួយវិញទៀតផ្អែកតាមសំណុំរឿងផ្សេងទៀតក៏ចោទមកបទល្មើសលួចដែរ។ ដូច្នេះហើយ ក្រោយពីការប្រព្រឹត្តអំពើរបស់គាត់ គាត់បានដឹងពីទោសកំហុស ហើយបច្ចុប្បន្ននេះគាត់បានកែខ្លួននៅក្នុងពន្ធនាគារ រហូតដល់ពន្ធនាគារឱ្យគាត់ធ្វើជាប្រធានបន្ទប់ មិនដែលមានទោសពិន័យណាមួយឡើយ ហើយគាត់បច្ចុប្បន្នមានកូនតូច។ ដូចនេះ ក្នុងនាមខ្លួនជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទទាំងឈ្មោះ [redacted] ឡេងប៊ុនវ៉ា និងឈ្មោះ [redacted] សុខី ស្នើសុំឱ្យប្រធានក្រុមប្រឹក្សាជំនុំជម្រះមេត្តាសម្រេចកែប្រែបទចោទពីបទៈ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា តាមមាត្រា ៣៥៣ និងមាត្រា ៣៥៧ ទៅមាត្រា ៣៥៣ និងមាត្រា ៣៥៦ បទ លួច ធម្មតាវិញ។ មួយទៀតស្នើសុំឱ្យក្រុមប្រឹក្សាមេត្តាពិនិត្យពីស្ថានសម្រាលទោសដល់កូនក្តីខ្លួនតាមបញ្ញត្តិមាត្រា ៩៣ និងមាត្រា ៩៤ នៃក្រមព្រហ្មទណ្ឌ ដោយសារគាត់សហការជាមួយសមត្ថកិច្ច និងចម្លើយសារភាពរបស់គាត់នៅគ្រប់ដំណាក់ទាំងអស់គឺពុំមានអ្វីស្មុគស្មាញនោះទេ។ មួយទៀតស្នើសុំឱ្យលោកស្រីចៅក្រមមេត្តាជួយបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនផង។

-លោកស្រី [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទឈ្មោះ [redacted] រ៉ាប៊ូ បានធ្វើសេចក្តីសន្និដ្ឋានថាៈ ដោយសារកូនក្តីខ្លួនបានឆ្លើយសារភាពនូវអង្គហេតុនេះហើយ ដូចនេះ ស្នើសុំឱ្យលោកស្រីចៅក្រមមេត្តាជួយបន្ធូរបន្ថយទោសដល់កូនក្តីខ្លួនផង។

-ជនជាប់ចោទឈ្មោះ [redacted] ឡេងប៊ុនវ៉ា ហៅ ផាន់ណា និយាយសំដីចុងក្រោយថាៈ សូមឱ្យតុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់រូបខ្លួនផង ព្រោះខ្លួនដឹងកំហុសហើយ។

-ជនជាប់ចោទឈ្មោះ [redacted] រ៉ាប៊ូ និយាយសំដីចុងក្រោយថាៈ សូមឱ្យតុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់រូបខ្លួនផង ព្រោះខ្លួនដឹងកំហុសហើយ។

-ជនជាប់ចោទឈ្មោះ [redacted] សុខី និយាយសំដីចុងក្រោយថាៈ ចំពោះរឿងនេះ ខ្លួនស្នើសុំឱ្យតុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់រូបខ្លួនព្រោះខ្លួនដឹងកំហុសហើយ។

-ជនជាប់ចោទឈ្មោះ [redacted] សុធារិទ្ធ និយាយសំដីចុងក្រោយថាៈ ចំពោះរឿងនេះ ខ្លួនស្នើសុំឱ្យតុលាការមេត្តាជួយបន្ធូរបន្ថយទោសដល់រូបខ្លួនព្រោះខ្លួនដឹងកំហុសហើយ។

-ក្រោយពីបានស្តាប់ចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] ឡេងប៊ុនវ៉ា [redacted] រ៉ាប៊ូ [redacted] សុខី និងឈ្មោះ [redacted] សុធារិទ្ធ

-ក្រោយពីបានស្តាប់អំណានចម្លើយរបស់ដើមបណ្តឹងឈ្មោះ [redacted] សាលៈ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទ

-ក្រោយពីបានស្តាប់សំដីចុងក្រោយរបស់ជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ



Scanned with CamScanner

# សំអាងហេតុ

១-តុលាការបានទទួលសំណុំរឿងព្រហ្មទណ្ឌលេខ ១២៥ ចុះថ្ងៃទី០៨ ខែមករា ឆ្នាំ២០១៩ មកជំនុំជម្រះតាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៥៨០៤ "ជ" ជ.ជ ចុះថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០១៨ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងរាជធានីភ្នំពេញដែលបានចោទប្រកាន់លើជនជាប់ចោទឈ្មោះ [redacted] ឡេងប៊ុនរ៉ា ហៅ ផាន់ណា ភេទប្រុស អាយុ៣១ឆ្នាំ ជនជាតិខ្មែរ ឈ្មោះ [redacted] រ៉ាប៊ូ ភេទប្រុស អាយុ៣២ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ[redacted] សុឌី ភេទស្រី អាយុ២៣ឆ្នាំ ជនជាតិខ្មែរ ពីបទ: **លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា** ប្រព្រឹត្តនៅចំណុចមុខផ្ទះលេខ២២ ផ្លូវបេតុង ភូមិម៉ល សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។ ឈ្មោះ [redacted] សុថារិទ្ធ ភេទប្រុស អាយុ៣១ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ [redacted] ណារ៉ុង ភេទប្រុស អាយុ៣៣ឆ្នាំ ជនជាតិខ្មែរ ពីបទ: ទទួលផលចោរកម្ម ប្រព្រឹត្តនៅក្នុងការស៊ីណូណាហ្គាវើល រាជធានីភ្នំពេញ កាលពីអំឡុងខែតុលា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ។

២-កាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ វេលាម៉ោង ០២ និង ០០ នាទី នៅចំណុចផ្ទះលេខ២២ ផ្លូវបេតុង ភូមិម៉ល សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ខណៈពេលឈ្មោះ [redacted] សាល បានចតនៅមុខផ្ទះនូវរថយន្តមួយគ្រឿងម៉ាក កាមរី ពណ៌ទឹកមាស សេរីឆ្នាំ២០០៣ ពាក់ស្លាកលេខ ភ្នំពេញ ២AB-៨១៣១ ត្រូវបានឈ្មោះ[redacted] ឡេងប៊ុនរ៉ា ហៅ ផាន់ណា ភេទប្រុស ធ្វើសកម្មភាពលួចយករថយន្តដោយកាច់បំបែកសោទ្វាររថយន្ត និងសោកុងតាក់រថយន្ត របស់ជនរងគ្រោះដោយឈ្មោះ[redacted] រ៉ាប៊ូ ភេទប្រុស និងឈ្មោះ[redacted] សុឌី ភេទស្រី ជាអ្នកមើលផ្លូវ។បន្ទាប់ពីលួចបានហើយឈ្មោះ [redacted] ឡេងប៊ុនរ៉ា បានយករថយន្តនោះទៅលក់ឱ្យឈ្មោះ[redacted] សុថារិទ្ធ និងឈ្មោះ [redacted] ណារ៉ុង ហើយក៏បានចែកលុយគ្នា ប្រាកដមែន។

៣-ជនជាប់ចោទឈ្មោះ [redacted] ឡេងប៊ុនរ៉ា បានឆ្លើយថាសារភាពថា នៅយប់កើតហេតុនោះ គឺពួកខ្លួនពិតជាបានប្រព្រឹត្តនូវលួចយករថយន្តរបស់គេដោយកាច់បំបែកសោទ្វាររថយន្ត និងសោកុងតាក់រថយន្ត នៅចំណុចផ្ទះលេខ ២២ ផ្លូវបេតុង ភូមិម៉ល សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ប្រាកដមែន។

៤-ជនជាប់ចោទឈ្មោះ [redacted] រ៉ាប៊ូ បានឆ្លើយសារភាពថា នៅថ្ងៃកើតហេតុនោះគឺខ្លួនបានជិះរថយន្តទៅជាមួយឈ្មោះ[redacted] ឡេងប៊ុនរ៉ា និងឈ្មោះ [redacted] សុឌី ប្រាកដមែន។ លុះជិះទៅដល់ចំណុចនៅចំណុចផ្ទះលេខ២២ ផ្លូវបេតុង ភូមិម៉ល សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ បានឃើញរថយន្តគេចតទុកនៅមុខផ្ទះ ហើយឈ្មោះ លឹម ឡេងប៊ុនរ៉ា ជាអ្នកធ្វើសកម្មភាពលួចយក ហើយខ្លួន និងឈ្មោះ[redacted] សុឌី ជាអ្នកមើលផ្លូវឱ្យ។

៥-ជនជាបចោទឈ្មោះ [redacted] សុឌី បានឆ្លើយសារភាពថា នៅថ្ងៃកើតហេតុគឺខ្លួនបានទៅជាមួយឈ្មោះ [redacted] ឡេងប៊ុនរ៉ា និងឈ្មោះ [redacted] រ៉ាប៊ូ បានជិះរថយន្តទៅនៅចំណុចនៅចំណុចផ្ទះលេខ២២ ផ្លូវបេតុង ភូមិម៉រ សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ ដោយឈ្មោះ[redacted] ឡេងប៊ុនរ៉ា ជាអ្នកធ្វើសកម្មភាពលួចយករថយន្ត ដោយខ្លួន និងឈ្មោះ [redacted] រ៉ាប៊ូ ជាអ្នកមើលផ្លូវឱ្យ។

៦-ជនជាប់ចោទឈ្មោះ[redacted] សុថារិទ្ធ បានឆ្លើយសារភាពថា កាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ វេលាម៉ោង ៧ ព្រឹក ឈ្មោះ[redacted] ឡេងប៊ុនរ៉ា បានយករថយន្តទៅដាក់បញ្ចាំឱ្យឈ្មោះ[redacted] ណារ៉ុង រួចហើយឈ្មោះ[redacted] ឡេងប៊ុនរ៉ា



Scanned with CamScanner

បានឱ្យប្រាក់មកខ្លួនចំនួន ១០០$។

៧-ដើមបណ្តឹងឈ្មោះ [redacted] សាល បានឆ្លើយថា: នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០១៨ វេលាម៉ោង ៥ ខ្លួនពុំបានបើករថយន្តនេះទៅណាទេ គឺខ្លួននិងក្រុមគ្រួសារទុកចតនៅមុខផ្ទះរហូត។ លុះម៉ោង ២ ទៀបភ្លឺ ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ ខ្លួនភ្ញាក់ពីដេក អើតមើលរថយន្តខ្លួន ឃើញនៅកន្លែងដែលចតទុកហើយខ្លួនក៏ចូលដេញវិញ។ លុះដល់ម៉ោង ៦ និង៣០នាទីព្រឹក ខណៈពេលដែលខ្លួនត្រូវជូនកូនទៅសាលា ស្រាប់តែមិនឃើញឡាន ហើយបន្ទាប់មកខ្លួនក៏ដាក់ពាក្យបណ្តឹងនៅប៉ុស្តិ៍រដ្ឋបាលដង្កោតែម្តង។

៨-យោងតាមរបាយការណ៍សំយោគលេខ ៤៤៩/១៨ រ.ប.ក ចុះថ្ងៃទី១៩ ខែធ្នូ ឆ្នាំ២០១៨ របស់ការិយាល័យនគរបាលព្រហ្មទណ្ឌកម្រិតស្រាល នៃស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បានសន្និដ្ឋានថា: ជនសង្ស័យឈ្មោះ [redacted] ឡេងប៊ុនរ៉ា ហៅ ផាន់ណា ភេទប្រុស អាយុ៣១ឆ្នាំ ជនជាតិខ្មែរ ឈ្មោះ [redacted] វ៉ាប៊ូ ភេទប្រុស អាយុ៣២ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ [redacted] សុឌី ភេទស្រី អាយុ២៣ឆ្នាំ ជនជាតិខ្មែរ ពិតជាប្រព្រឹត្តនូវអំពើ លួច(រថយន្តម៉ាកតូយ៉ូតាកាមរី ពណ៌ទឹកមាស សេរីឆ្នាំ២០០៣ លេខតួ ៧៤៦៦៦០៧ លេខម៉ាស៊ីន ១៩០៤៧៨ ពាក់ស្លាកលេខ ភ្នំពេញ ២AB-៨១៣១) ប្រព្រឹត្តនៅចំណុចមុខផ្ទះលេខ២២ ផ្លូវបេតុង ភូមិម័ល សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ វេលាម៉ោងប្រហែល ០៣ និង១០ នាទីទៀបភ្លឺ ប្រាកដមែន។ ចំណែកឈ្មោះ [redacted] សុថារិទ្ធ ភេទប្រុស អាយុ៣១ឆ្នាំ និងឈ្មោះ [redacted] ណារ៉ុង ហៅ ស្វិត ភេទប្រុស អាយុ៣៣ឆ្នាំ ពីបទ: ទទួលផលចោរកម្មក្នុងអំពើលួច(រថយន្តម៉ាកតូយ៉ូតាកាមរី ពណ៌ទឹកមាស សេរីឆ្នាំ២០០៣ លេខតួ ៧៤៦៦៦០៧ លេខម៉ាស៊ីន ១៩០៤៧៨ ពាក់ស្លាកលេខ ភ្នំពេញ ២ AB-៨១៣១) ប្រព្រឹត្តនៅចំណុចមុខផ្ទះលេខ២២ ផ្លូវបេតុង ភូមិម័រ សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី ២៦ ខែតុលា ឆ្នាំ២០១៨ វេលាម៉ោងប្រហែល ០៣ និង១០ នាទី។

៩-យោងតាមចម្លើយសារភាពរបស់ជនជាប់ចោទ ជនរងគ្រោះ និងរបាយការណ៍របស់សមត្ថកិច្ចព្រមទាំងឯកសារភស្តុតាងផ្សេងៗក្នុងសំណុំរឿងឃើញថា មានលក្ខណៈស៊ីសង្វាក់គ្នាបញ្ជាក់ថាកាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ ជនជាប់ចោទឈ្មោះ [redacted] ឡេងប៊ុនរ៉ា ហៅ ផាន់ណា ភេទប្រុស ឈ្មោះ [redacted] វ៉ាប៊ូ ភេទប្រុស និងឈ្មោះ [redacted] សុឌី ភេទស្រី ពិតជាបានប្រព្រឹត្ត អំពើលួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចមុខផ្ទះលេខ២២ ផ្លូវបេតុង ភូមិម័ល សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ ប្រាកដមែន។ ដោយឡែកចំពោះឈ្មោះ [redacted] សុថារិទ្ធ ភេទប្រុស និងឈ្មោះ [redacted] ណារ៉ុង ហៅ ស្វិត ភេទប្រុស ពីបទ: ទទួលផលចោរកម្មក្នុងអំពើលួច ប្រព្រឹត្តនៅចំណុចមុខផ្ទះលេខ២២ ផ្លូវបេតុង ភូមិម័ល សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ ប្រាកដមែន។

១០-សកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ឡេងប៊ុនរ៉ា ហៅ ផាន់ណា ភេទប្រុស បានដែលបានយកដែកគ្លឹះចាក់សោរឡាន ហើយឈ្មោះ [redacted] វ៉ាប៊ូ និងឈ្មោះ [redacted] សុឌី ជាអ្នកមើលផ្លូវឱ្យឈ្មោះ [redacted] ឡេងប៊ុរ៉ា ដែលបានលួចទ្រព្យសម្បត្តិអ្នកដទៃដោយគ្មានការអនុញ្ញាត ត្រូវបានច្បាប់កំណត់ថាបទល្មើស លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ហើយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ០៣(បី)ឆ្នាំ ទៅ ១០(ដប់) ឆ្នាំ តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។ បន្ទាប់ពីលួចបានឈ្មោះ [redacted] សុថារិទ្ធ ភេទប្រុស និងឈ្មោះ [redacted] ណារ៉ុង ហៅ ស្វិត ភេទប្រុស បានទទួលទិញរថយន្តពីឈ្មោះ [redacted] ឡេងប៊ុនរ៉ា និងបានទទួលផលចំណែកពីអំពើនេះ ត្រូវបាន

ច្បាប់កំណត់ថាជាបទល្មើស ទទួលផលចោរកម្ម ដែលមានចែង និងផ្តន្ទាទោសដាក់ពន្ធនាគារពី ២(ពីរ)ឆ្នាំ ទៅ ៥(ប្រាំ)ឆ្នាំ តាមបញ្ញត្តិមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ។

១១-ជនជាប់ចោទឈ្មោះ [redacted] ឡេងប៊ុនវ៉ា ឈ្មោះ [redacted] វ៉ាប៊ូ និងឈ្មោះ [redacted] សុធី និងឈ្មោះ [redacted] សុថារិទ្ធ ជានីតិជន មានកាយសម្បទាគ្រប់គ្រាន់ និងមានស្មារតីគ្រប់គ្រាន់ក្នុងការប្រព្រឹត្តនូវសកម្មភាពរបស់ខ្លួន ប៉ុន្តែជននេះនៅតែប្រព្រឹត្តដោយចេតនាទុច្ចរិតប្រាកដមែន។

១២-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា: មានមូលដ្ឋានគ្រប់គ្រាន់ដើម្បីបញ្ជាក់ពីតម្រុយពិរុទ្ធភាពរបស់ជនជាប់ចោទ។

១៣-មេធាវីការពារសិទ្ធិឱ្យជនជាប់ចោទទាំងបីនាក់បានធ្វើសេចក្តីសន្និដ្ឋានថាស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះសម្រេចកែប្រែបទចោទពីបទ: លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ មកបទ: លួច តាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៦ នៃក្រមព្រហ្មទណ្ឌវិញនោះ គឺពុំមានលក្ខណៈត្រឹមត្រូវនោះទេដោយហេតុថា សកម្មភាពរបស់ជនជាប់ចោទឈ្មោះ [redacted] ឡេងប៊ុនវ៉ា បានយកដែកនិងសោរទៅចាក់គាស់ ដើម្បីលួចយករថយន្តបាន ហើយចំណែកឈ្មោះ [redacted] សុធី និងឈ្មោះ លន់ វ៉ាប៊ូ ជាអ្នកមើលផ្លូវដើម្បីឱ្យឈ្មោះ [redacted] ឡេងប៊ុនវ៉ា លួចបានសម្រេច។

១៤-ជនជាប់ចោទឈ្មោះ [redacted] ណារ៉ុង ហៅ ស្វិត ពិតជាបានចូលរួមក្នុងការទិញរថយន្តដែលឈ្មោះ [redacted] ឡេងប៊ុនវ៉ា លួចពីគេបាន សបញ្ជាក់ឱ្យឃើញថា ឈ្មោះ [redacted] ណារ៉ុង ពិតជាបានចូលរួមក្នុងអំពើសមគំនិតទទួលផលចោរកម្ម គប្បីតុលាការចេញដីកាបង្គាប់ឱ្យចាប់តាមបញ្ញត្តិមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

១៥-មានពិរុទ្ធភាពគ្រប់គ្រាន់លើជនជាប់ចោទឈ្មោះ [redacted] ឡេងប៊ុនវ៉ា ហៅ ផាន់ណា ភេទសប្រុស អាយុ៣១ឆ្នាំ ជនជាតិខ្មែរ ឈ្មោះ [redacted] វ៉ាប៊ូ ភេទប្រុស អាយុ៣២ឆ្នាំ ជនជាតិខ្មែរ និងឈ្មោះ [redacted] សុធី ភេទស្រី អាយុ២៣ឆ្នាំ ជនជាតិខ្មែរ ពីបទ: លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើប្រព្រឹត្តនៅចំណុចមុខផ្ទះលេខ២២ ផ្លូវបេតុងភូមិម័ល សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។ ឈ្មោះ [redacted] សុថារិទ្ធ ភេទប្រុស អាយុ៣១ឆ្នាំ និងឈ្មោះ [redacted] ណារ៉ុង ភេទប្រុស អាយុ៣៣ឆ្នាំ ជនជាតិខ្មែរ ពីបទ: ទទួលផលចោរកម្ម ប្រព្រឹត្តនៅចំណុចក្នុងការស៊ីណូណាហ្គោ រាជធានីភ្នំពេញ កាលពីអំឡុងខែតុលា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ។

១៦-យោងតាមកំណត់ហេតុប្រគល់រថយន្តបណ្តោះអាសន្ន ចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៨ នៅដំណាក់កាលរបស់មន្ត្រីនគរបាលយុត្តិធម៌ បានបញ្ជាក់ថា រថយន្តមួយគ្រឿងម៉ាក តូយ៉ូតាកាមរី ពណ៌ទឹកមាស សេរីឆ្នាំ២០០៣ លេខម៉ាស៊ីន ៧៤៦៦៦០៧ លេខតួ ៩៣៤១៩០៤៧៨ ពាក់ស្លាកលេខ ភ្នំពេញ ២AB-៨១៣១ បានប្រគល់ទៅឱ្យឈ្មោះ ទេព សាល ដែលជាម្ចាស់រថយន្តវិញហើយ គប្បីតុលាការមិនលើកយកមកពិចារណាទេ។

១៧-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សាល ពុំបានចូលតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅចំពោះមុខតុលាការទេ ហើយដើមបណ្តឹងបានទទួលយករថយន្តរបស់ខ្លួនទៅវិញហើយតាមកំណត់ហេតុចុះថ្ងៃទី០៦ ខែវិច្ឆិកា ឆ្នាំ២០១៨ គប្បីតុលាការមិនពិចារណាពីសំណងទេ។



Scanned with CamScanner

## ហេតុដូច្នេះ សម្រេច

១-ផ្តន្ទាទោស៖

ក-ឈ្មោះ [redacted] ឡេងប៊ុនរ៉ា ហៅ ផាន់ណា ភេទប្រុស អាយុ៣១ឆ្នាំ ជនជាតិខ្មែរ មានទីកន្លែងកំណើត[redacted] ក្រុងភ្នំពេញ បច្ចុប្បន្នកំពុងឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី១ ឪពុកឈ្មោះ [redacted] ប៊ុនធី "រ" ម្តាយឈ្មោះ [redacted] យឿន "រ" ប្រពន្ធឈ្មោះ [redacted] សុគន្ធា ជានីតិជន ទោសពីមុនធ្លាប់ជាប់ពន្ធនាគាររយៈពេល ០១ឆ្នាំ ពីបទៈ ចែកចាយគ្រឿងញៀន។

**ដាក់ពន្ធនាគារកំណត់ ៤(បួន)ឆ្នាំ។**

ខ-ឈ្មោះ [redacted] រាំបូ ភេទប្រុស អាយុ៣២ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើត[redacted] ក្រុងភ្នំពេញ បច្ចុប្បន្នកំពុងឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី១ ឪពុកឈ្មោះ [redacted] សារឿន "រ" ម្តាយឈ្មោះ [redacted] ថាន "រ" ប្រពន្ធឈ្មោះ ណាភ "រ" ទោសពីមុនគ្មាន ជានីតិជន។

**ដាក់ពន្ធនាគារកំណត់ ៤(បួន)ឆ្នាំ។**

គ-ឈ្មោះ [redacted] សុខី ភេទស្រី អាយុ២៣ឆ្នាំ ជនជាតិខ្មែរ មានទីកន្លែងកំណើ[redacted] ក្រុងភ្នំពេញ បច្ចុប្បន្នកំពុងឃុំខ្លួននៅមណ្ឌលអប់រំកែប្រែទី ឪពុកឈ្មោះ [redacted] ណារិន "រ" ម្តាយឈ្មោះ [redacted] ចាន់ថន "រ" ប្តីឈ្មោះ វិបុល ពន្លក "រ" ជានីតិជន ទោសពីមុនគ្មាន។

**ដាក់ពន្ធនាគារកំណត់ ៤(បួន)ឆ្នាំ។**

ជាប់ចោទពីបទៈ លួចមានស្ថានទម្ងន់ទោសដោយសារការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅចំណុចមុខផ្ទះលេខ២២ ផ្លូវបេតុង ភូមិម៉ល សង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ កាលពីថ្ងៃទី២៦ ខែតុលា ឆ្នាំ២០១៨ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៥៣ និងមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

ឃ-ឈ្មោះ [redacted] សុថារិទ្ធ ភេទប្រុស អាយុ៣១ឆ្នាំ ជនជាតិខ្មែរ ទីកន្លែងកំណើត[redacted] ក្រុងភ្នំពេញ មានទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះលេខ ២២ង ផ្លូវលេខ ៥៩៨ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ឪពុកឈ្មោះ [redacted] ផាន់ណា "រ" ម្តាយឈ្មោះ [redacted] សុម៉ាលី "រ" ប្រពន្ធឈ្មោះ [redacted] កែវរង្សា "រ" កូនគ្មាន ទោសពីមុនគ្មាន ជានីតិជន។

**ដាក់ពន្ធនាគារកំណត់ ៣(បី)ឆ្នាំ។**

ង-ឈ្មោះ [redacted] ណារ៉ុង ភេទប្រុស អាយុ៣៣ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ មានទីកន្លែងកំណើតនៅ [redacted] ក្រុងភ្នំពេញ មានទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះជួល សង្កាត់ចតុមុខ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ឪពុកឈ្មោះ[redacted]ណារិន "រ" ម្តាយឈ្មោះ[redacted]គន្ធា "រ" ទោសពីមុនគ្មាន ជានីតិជន។

**ដាក់ពន្ធនាគារកំណត់ ៣(បី)ឆ្នាំ។**

ជាប់ចោទពីបទៈ ទទួលផលចោរកម្ម ប្រព្រឹត្តនៅចំណុចក្នុងកាស៊ីណូណាហ្គារាជធានីភ្នំពេញ កាលពីអំឡុងខែតុលា ឆ្នាំ២០១៨ បទល្មើសព្រហ្មទណ្ឌដែលមានចែង និងឱ្យផ្តន្ទាទោសតាមបញ្ញត្តិមាត្រា ៣៩៩ និងមាត្រា ៤០០ នៃក្រមព្រហ្មទណ្ឌ។

២-បង្គាប់ឱ្យចាប់ខ្លួន និងឃុំខ្លួនលើឈ្មោះ [redacted] ណារ៉ុង ហៅ ស្វិត ភេទប្រុស អាយុ៣៣ឆ្នាំ ជនជាតិខ្មែរ តាមបញ្ញត្តិមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៧ ខែមករា ឆ្នាំ២០២០ និងប្រកាសសាលក្រមជាសាធារណៈ នៅថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២០ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ឡេងប៊ុនវ៉ា ហៅ ផាន់ណា ឈ្មោះ [redacted] វាំបូ ឈ្មោះ [redacted] សុខី និងឈ្មោះ [redacted] សុថារិទ្ធ និងកំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ណារ៉ុង ហៅ ស្វិត។ ទុកសិទ្ធិប្ដឹងទាស់ និងប្ដឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

| ក្រឡាបញ្ជីសវនាការ | ចៅក្រមប្រឹក្សា | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សាជំនុំជម្រះ |
|---|---|---|---|
| ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា | ហត្ថលេខានិងត្រា |

[redacted]

---

បានឃើញ
ប្រធានក្រុមប្រឹក្សាជំនុំជម្រះ

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃ ចន្ទ ៩កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី០២ ខែមីនា ឆ្នាំ២០២០
ក្រឡាបញ្ជី

[redacted]